វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

ក្រសួងយុត្តិធម៌ និងក្រសួងបរិស្ថាន

លេខ :៤០ ប្រក.កយបស្ថ /ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៣

ប្រកាសរួមស្តីពីការដាក់អោយប្រើប្រាស់គំរូសំណុំលិខិតដោះស្រាយបទល្មើសបរិស្ថានដល់មន្ត្រីនគរបាលយុត្តិធម៌របស់ក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/ ៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងស្ថានបរិស្ថាន
- បានឃើញព្រះរាជក្រម លេខ នស /រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតតំបន់ការពារធម្មជាតិ
- បានឃើញក្រឹត្យលេខ ២១ក្រ. ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៣ ស្តីពីនីតិវិធីព្រហ្មទណ្ឌ
- បានឃើញព្រះរាជក្រម លេខ នស/រកម/ ០១០២ /០០៥ ចុះថ្ងៃទី ១០ខែ មករា ឆ្នាំ ២០០២ស្តីពីវិសោធនកម្ម មាត្រា៣៦ មាត្រា៣៨ មាត្រា៩០ និងមាត្រា ៩១ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ
- បានឃើញក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ប្រកាសឱ្យប្រើច្បាប់ស្តីពីចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ/បក ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៥៧អនក្រ/បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ/បក ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការត្រួតពិនិត្យការបំពុលទឹក
- បានឃើញអនុក្រឹត្យលេខ ៣៦ អនក្រ/បក ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការគ្រប់គ្រងសំណល់រឹង
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ/បក ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និង ការរំខានដោយសំលេង
- តាមសំណើររបស់ក្រសួងបរិស្ថានលេខ ៦១២ សណ / បស្ថចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ ២០០២

Downloaded from http://www.khmerlaws.com

វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

**សំរេច**

ប្រការ ១ :

ត្រូវបានទទួលស្គាល់ដោយច្បាប់ ជាមន្ត្រីនគរបាលយុត្តិធម៌ ឬ អាចបំពេញភារកិច្ចជាមន្ត្រីនគរបាលយុត្តិធម៌ ដល់មន្ត្រីក្រសួងបរិស្ថាន រួមមាន :

- អគ្គនាយក អគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស
- ប្រធាន អនុប្រធាននាយកដ្ឋាន និងប្រធាន អនុប្រធានការិយាល័យកិច្ចការច្បាប់ នៃនាយកដ្ឋានផែនការ និងកិច្ចការច្បាប់
- ប្រធាន អនុប្រធាន នាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ និង ប្រធាន អនុប្រធានៈ
  - ការិយាល័យឧទ្យានជាតិ និង ដែនជំរកសត្វព្រៃ
  - ការិយាល័យតំបន់ដីសើម ទីជំរាល និង តំបន់ឆ្នេរ
  - នាយក នាយករងស្នាក់ការតំបន់ការពារធម្មជាតិ នៃ នាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ
- ប្រធាន អនុប្រធាន នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន និងប្រធាន អនុប្រធាន
  - ការិយាល័យគ្រប់គ្រងគុណភាពទឹក និង ដី
  - ការិយាល័យសំណល់រឹង និងសារធាតុប្រកបដោយគ្រោះថ្នាក់
  - ការិយាល័យគ្រប់គ្រងគុណភាពខ្យល់ សំលេង និង រំញ័រ នៃនាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន
- ប្រធាន អនុប្រធាន មន្ទីរបរិស្ថានខេត្ត-ក្រុង និងប្រធាន អនុប្រធានការិយាល័យត្រួតពិនិត្យការបំពុលបរិស្ថាន និង អប់រំផ្សព្វផ្សាយពត៌មានបរិស្ថាន

ប្រតិបត្តិការរបស់មន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងបរិស្ថាន ត្រូវស្ថិតនៅក្រោមការដឹកនាំរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងបរិស្ថាន និង ការដឹកនាំសម្របសម្រួលរបស់ព្រះរាជអាជ្ញាលើនីតិវិធី និង វិធានស៊ើបអង្កេត ដើម្បីធានាការចោទប្រកាន់ឱ្យមានប្រសិទ្ធិភាព ក្រោមការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ។

ប្រការ២ :

អនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌របស់ក្រសួងបរិស្ថានដូចមានចែងក្នុងប្រការ ១ ខាងលើប្រើប្រាស់ជាផ្លូវការនូវគំរូសំណុំលិខិតដោះស្រាយបទល្មើសបរិស្ថាន រួមមាន :

- កំណត់ហេតុបណ្តឹង របាយការណ៍
- កំណត់ហេតុស្តាប់កសិណសាក្សី
- កំណត់ហេតុបទល្មើសជាក់ស្តែង
- កំណត់ហេតុប្រមូល និងឃាត់ ទុកវត្ថុតាង នៃបទល្មើសជាក់ស្តែង
- កំណត់ហេតុស្តីពីការយកគំរូតាងមកវិភាគ
- របាយការណ៍វាយតំលៃពីការខូតខាតបរិស្ថានដែលបណ្តាលមកពីបទល្មើស
- កំណត់ហេតុស្តីពីការចាប់ខ្លួន ឃាត់ខ្លួនពីបទល្មើសជាក់ស្តែង
- កំណត់ហេតុប្រគល់ និងទទួលគ្រប់គ្រងវត្ថុតាង
- កំណត់ហេតុប្រគល់ និងទទួលជនដែលត្រូវចាប់ខ្លួន ឃាត់ខ្លួនពីបទល្មើសជាក់ស្តែង
- កំណត់ហេតុសួរចម្លើយជនល្មើស
- វិញ្ញាបនប័ត្រកោសល្យវិច័យគំរូតាង
- កំណត់ហេតុចុះពិនិត្យទីកន្លែងកើតហេតុ

Downloaded from http://www.khmerlaws.com

- កំណត់ហេតុសាកសួរបំភ្លឺ
- កំណត់ហេតុ ស្តីពីការឆែកឆេរ
- របាយការណ៍សំយោគ
- កំណត់ហេតុនៃបទល្មើស
- សាលកប័ត្រទោសទណ្ឌ
- ព្រឹត្តិប័ត្រព័ត៌មានជនល្មើស
- សេចក្តីសំរេចស្តីពីការពិន័យអន្តរការណ៍លើជនល្មើស
- ដីកាបញ្ជូន ឬ ដីការអមទៅព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង

ដូចមានភ្ជាប់មកជាមួយនេះ ដើម្បីឱ្យមន្ត្រីនគបាលយុត្តិធមិ របស់ក្រសួងបរិស្ថានងាយស្រួលបំពេញបែបបទប្រតិបត្តិការរបស់ខ្លួន ឱ្យបានសមស្របតាមនីតិវិធីច្បាប់ និង លិខិតបទដ្ឋានគតិយុត្តដែលនៅជាធរមានបញ្ញត្តិ ។

ប្រការ ៣:

មន្ត្រីនគរបាលយុត្តិធមិរបស់ក្រសួងបរិស្ថានដូចមានចែងក្នុងប្រការ១ ខាងលើ តុលាការគ្រប់ខេត្ត-ក្រុង និង អយ្យការអមតុលាការខេត្ត-ក្រុង មានភារកិច្ចអនុវត្តតាមគំរូសំណុំលិខិត ដោះស្រាយបទល្មើសបរិស្ថានដូចមានចែងក្នុងប្រការ ២ ខាង លើតាមភារកិច្ចរៀង១ ខ្លួន ។

ប្រការ ៤ :

ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

Downloaded from http://www.khmerlaws.com